ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ✻ ៧៧

ក្រសួងធនធានទឹក និងឧតុនិយម
លេខ ១៤៥ សជណ ទខឧ

# សេចក្តីជូនដំណឹង
## ស្តីពី ការព្យាករស្ថានភាពអាកាសធាតុ នារដូវវស្សា ឆ្នាំ ២០១៥

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបអំពីស្ថានភាពអាកាសធាតុរដូវវស្សាឆ្នាំ 2015 ដូចខាងក្រោម ៖

**១~ ធាតុភូតសកល ៖**

ចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ 2015 សីតុណ្ហភាពលើផ្ទៃសមុទ្រត្រង់ចំណុចខ្សែអេក្វាទ័រ មានកម្រិតប្រហាក់ប្រហែលនឹងមធ្យមភាគច្រើនឆ្នាំ ។ ប៉ុន្តែ ចាប់ពីខែកក្កដា ដល់ខែតុលា ឆ្នាំ 2015 សីតុណ្ហភាពមានកម្រិតទាបជាងមធ្យមភាគច្រើនឆ្នាំ និងទាបជាងឆ្នាំ 2014 ។

ធាតុភូតសកលដូចបានជម្រាបជូនខាងលើ នឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា ដោយបង្កឱ្យមានភ្លៀងកក់ខែបន្តធ្លាក់ក្នុងក្របខ័ណ្ឌទូទាំងប្រទេសរហូតដល់ចុងខែមេសា ឯរដូវវស្សានាឆ្នាំ 2015 នេះ មានស្ថានភាពដូចខាងក្រោម ៖

**២~ ស្ថានភាពទូទៅ និងការព្យាករអាកាសធាតុនារដូវវស្សាឆ្នាំ ២០១៥ នៅកម្ពុជា ៖**

- **តំបន់មាត់សមុទ្រ និងតំបន់វាលទំនាប** រដូវវស្សានឹងចាប់ផ្តើមនៅក្នុងសប្តាហ៍ទី 01 នៃខែឧសភា ។ **និងតំបន់ខ្ពង់រាប** រដូវវស្សានឹងចាប់ផ្តើមនៅដើមសប្តាហ៍ទី 02 នៃខែឧសភា ។
- ចាប់ពីខែមេសា ដល់ខែមិថុនា ភ្លៀងចាប់ផ្តើមធ្លាក់រាយប៉ាយពីកម្រិតតិចទៅបង្គួរ (ប្រហាក់ប្រហែលនឹងឆ្នាំ 2014) ។ **ក្នុងកំឡុងពេលនេះ អាចមានផ្គរ រន្ទះ និងខ្យល់កន្ត្រាក់ កើតឡើងច្រើន** ។
- **កួនរដូវប្រាំង** ៖ អាចនឹងកើតមានក្នុងរយៈពេលខ្លី ( ក្នុងសប្តាហ៍ទី 04 នៃខែមិថុនា ) នៅភាគខាងលិចនៃខេត្តតាកែវ កំពង់ស្ពឺ និងខេត្តកណ្តាល ។
- **ចាប់ពីខែកក្កដា ដល់ខែតុលា** បរិមាណទឹកភ្លៀងធ្លាក់រាយប៉ាយច្រើន ។ កម្រិតទឹកភ្លៀងអាចនឹងធ្លាក់ចុះច្រើនជាង ឆ្នាំ 2014 (ប្រហាក់ប្រហែលឆ្នាំ 2011) ។
- រដូវវស្សាឆ្នាំ 2015 នឹងបញ្ចប់នៅសប្តាហ៍ទី 03 នៃខែវិច្ឆិកា ។
- ក្នុងឆ្នាំ 2015 នេះ ព្យុះដែលកើតឡើងនៅក្នុងសមុទ្រប៉ាស៊ីហ្វិក អាចមានពី 25-27 ព្យុះ ហើយអាចមានឥទ្ធិពលច្រើនមកលើជ្រោយឥណ្ឌូចិន និងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានលើស្ថានភាពអាកាសធាតុជាប់ជាប្រចាំ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែម ជាបន្តបន្ទាប់ក្នុងករណីចាំបាច់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

លឹម_គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh